# ក្រឡេកមើលក្រោយ និងឆ្ពោះទៅមុខ

ប្រធានថូម៉ាស អេស ម៉នសុន

*យើងទាំងអស់គ្នាគួរតែឆ្ពោះទៅមុខនៅក្នុងការធ្វើនូវកិច្ចការរបស់ទ្រង់ ។*

ខ្ញុំគិតថានេះគឺជាសម័យប្រជុំដ៏មហិមា ។ សារលិខិតទាំងឡាយមានការបំផុសគំនិត តន្ត្រីពិរោះ ទីបន្ទាល់ទាំងឡាយស្មោះស្ម័គ្រ ។ ខ្ញុំគិតថាអ្នកដែលបានចូលរួមនៅក្នុងសម័យប្រជុំនេះ នឹងមិនអាចបំភ្លេចបានទេ--- នូវព្រះវិញ្ញាណដែលពួកយើងបានទទួល ។

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ អស់រយៈពេល 44 ឆ្នាំកន្លងទៅហើយ តាំងពីខែ តុលា ឆ្នាំ 1963 ដែលខ្ញុំឈរនៅវេទិកានៅក្នុងរោងឧបោសថ ដែលត្រូវបានគាំទ្រជាសមាជិកមួយរូប នៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ នៅក្នុងឱកាសនោះ ខ្ញុំបានប្រាប់អំពីសញ្ញាតូចមួយ ដែលខ្ញុំបានឃើញនៅលើវេទិកាមួយទៀត ។ ពាក្យនៅលើសញ្ញានោះមានដូចតទៅនេះថា: "នរណាដែលឈរនៅលើវេទិកានេះ ចូរឱ្យគាត់បន្ទាបខ្លួន" ។ ខ្ញុំអះអាងនឹងអ្នកថា ខ្ញុំមានចិត្តរាបសារដោយការហៅរបស់ខ្ញុំ មកក្នុងពួកដប់ពីរនាក់នៅពេលនោះ ។ ទោះជាយ៉ាងណា នៅពេលខ្ញុំឈរនៅលើ វេទិកានៅថ្ងៃ *នេះ* ខ្ញុំថ្លែងទៅកាន់អ្នកដោយដួងចិត្តរាបសារបំផុត ។ ខ្ញុំទទួលអារម្មណ៍ដាក់ការពឹងផ្អែករបស់ខ្ញុំទាំងស្រុងទៅលើព្រះអម្ចាស់ ។ ខ្ញុំស្វែងរកដោយរាបសារនូវការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលខ្ញុំចែកចាយជាមួយអ្នកនូវអារម្មណ៍ពីដួងចិត្តរបស់ខ្ញុំ ។

ទើបតែរយៈពេលពីរខែកន្លងទៅ យើងបាននិយាយលាដល់មិត្ត និងជាអ្នកដឹកនាំជាទីស្រឡាញ់របស់យើង លោក ហ្គរដុន ប៊ី ហ៊ិងគ្លី ដែលជាប្រធានទី 15 នៃសាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ជាអ្នកតំណាងដ៏ពូកែនៃសេចក្តីពិត ចំពោះពិភពលោកទាំងមូល និងជាទីស្រឡាញ់ដល់មនុស្សគ្រប់រូប ។ យើងនឹកលោក ។ បុរស ស្ត្រី និងកុមារជាង 53,000 នាក់បានធ្វើដំណើរទៅកាន់សាលដ៏ស្រស់ស្អាតរបស់ព្យាការីនៅក្នុងអគារនេះ ដើម្បីផ្តល់ការគោរពចុងក្រោយបំផុតរបស់ពួកគេ ចំពោះបុរសដ៏មហិមារបស់ព្រះអម្ចាស់ ដែលឥឡូវនេះជាចំណែកមួយនៃប្រវត្តិសាស្ត្រ ។

ព្រមជាមួយនឹងមរណភាពរបស់ប្រធាន ហ៊ិងគ្លី គណៈប្រធានទីមួយត្រូវបានរំសាយ ។ ប្រធាន អាវិរិង និងខ្ញុំដែលបានបំរើជាទីប្រឹក្សារបស់ប្រធាន ហ៊ិងគ្លី បានត្រឡប់ទៅកាន់កន្លែងរបស់យើងនៅក្នុងក្រុម នៃពួកសាវក ដប់ពីរនាក់ ហើយក្រុមនោះបានក្លាយទៅជាក្រុមអ្នកមានសិទ្ធិអំណាចជាអធិបតីនៃសាសនាចក្រ ។

នៅថ្ងៃសៅរ៍ ទី 2 ខែ កុម្ភៈ ឆ្នាំ 2008 កម្មវិធីបុណ្យសពសំរាប់ប្រធាន ហ៊ិងគ្លី ត្រូវបានប្រារព្ធធ្វើឡើងនៅក្នុងមជ្ឈមណ្ឌលសន្និសីទដ៏រុងរឿងនេះ--- ជាអគារមួយដែលនឹងនៅឈរធ្វើជាទីរំលឹកមួយ ចំពោះការមើលឃើញទុកជាមុន និងការនិមិត្តរបស់លោក ។ អំឡុងពេលបុណ្យសព ការគោរពសរសើរដ៏អស្ចារ្យ និងជាទីស្រឡាញ់ ត្រូវបានផ្តល់ដល់បុរសនៃព្រះអម្ចាស់រូបនេះ ។

នៅថ្ងៃបន្ទាប់ សាវកនៅរស់ដែលបានតែងតាំងទាំង 14 រូបនៅលើផែនដី បានប្រជុំគ្នានៅក្នុងបន្ទប់ខាងលើ នៃព្រះវិហារបរិសុទ្ធសលត៍ លេក ។ យើងបានជួបគ្នាដោយមានការតមអាហារ និងការអធិស្ឋាន ។ អំឡុងពេលការប្រជុំគ្នា

ដ៏ឧឡារិក និងពិសិដ្ឋនោះ គណៈប្រធាននៃសាសនាចក្រ ត្រូវបានរៀបចំឡើងវិញ ស្របតាមអ្វីដែលធ្លាប់បានស្ថាបនាឡើង យ៉ាងល្អពីមុនមក តាមគំរូដែលព្រះអម្ចាស់ផ្ទាល់បានបង្កើតឡើង ។

សមាជិកនៃសាសនាចក្រនៅជុំវិញពិភពលោក បានប្រមូលផ្តុំគ្នាកាលពីម្សិលមិញនៅក្នុងការប្រជុំដ៏ឧឡារិកមួយ ។ អ្នកបានលើកដៃរបស់អ្នកផ្តល់មតិគាំទ្រ ដើម្បីអនុមតិលើសកម្មភាពដែលបានធ្វើនៅក្នុងការប្រជុំនៅក្នុងព្រះវិហារបរិសុទ្ធ ដែលខ្ញុំបានលើកឡើងមុននេះ ។ នៅពេលដៃរបស់អ្នកលើកឡើងឆ្ពោះទៅឋានសួគ៌ ចិត្តរបស់អ្នកត្រូវបានប៉ះ ។ ខ្ញុំទទួលអារម្មណ៍នៃសេចក្តីស្រឡាញ់ និងការគាំទ្ររបស់អ្នក ក៏ដូចជាការប្តេជ្ញាចិត្តរបស់អ្នកចំពោះព្រះអម្ចាស់ ។

ខ្ញុំដឹងដោយគ្មានចំងល់ បងប្អូនប្រុសស្រីទាំងឡាយរបស់ខ្ញុំ ថាព្រះមានព្រះជន្មរស់ ។ ខ្ញុំថ្លែងទីបន្ទាល់ដល់អ្នកថា នេះគឺជាកិច្ចការរបស់ទ្រង់ ។ ខ្ញុំថ្លែងទីបន្ទាល់ផងដែរថា ព្រះអង្គសង្គ្រោះរបស់យើង ព្រះយេស៊ូវគ្រីស្ទ គឺជាសិរីសារ នៃសាសនាចក្រនេះ ដែលមានព្រះនាមរបស់ទ្រង់ ។ ខ្ញុំដឹងថាបទពិសោធន៍ដ៏ផ្អែមល្ហែមបំផុតនៅក្នុងជីវិតនេះ គឺដើម្បីទទួលអារម្មណ៍ការបំផុសគំនិតរបស់ទ្រង់ នៅពេលទ្រង់ដឹកនាំយើងនៅក្នុងការចំរើននៃកិច្ចការរបស់ទ្រង់ ។ ខ្ញុំទទួលអារម្មណ៍បំផុសគំនិតទាំងនោះ កាលពីនៅជាប៊ីស្សពវ័យក្មេង ដែលបានដឹកនាំឱ្យទៅកាន់ផ្ទះទាំងឡាយ ដែលត្រូវការខាងវិញ្ញាណ--- ឬប្រហែលជាខាងសាច់ឈាម ។ ខ្ញុំទទួលអារម្មណ៍នោះទៀត នៅពេលធ្វើជាប្រធានបេសកកម្មនៅក្នុងទីក្រុងតូរុនតូ ប្រទេសកាណាដា ធ្វើការជាមួយនឹងអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យជាច្រើនដែលគឺជាសាក្សីនៅរស់ ហើយធ្វើទីបន្ទាល់ទៅកាន់ពិភពលោកថា កិច្ចការនេះ គឺជារបស់ព្រះ ហើយថាយើងត្រូវបានដឹកនាំដោយព្យាការីមួយរូប ។ ខ្ញុំទទួលអារម្មណ៍ទាំងនោះនៅក្នុងការបំរើរបស់ខ្ញុំ នៅក្នុងពួកដប់ពីរនាក់ និងនៅក្នុងគណៈប្រធានទីមួយ ហើយឥឡូវនេះជាប្រធាននៃសាសនាចក្រ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា យើងម្នាក់ៗ អាចទទួលអារម្មណ៍បំផុសគំនិតរបស់ព្រះអម្ចាស់ នៅពេលយើងរស់នៅដោយសក្តិសម និងព្យាយាមដើម្បីបំរើដល់ទ្រង់ ។

ខ្ញុំបានដឹងយ៉ាងច្បាស់អំពីបុរសទាំង 15 រូប ដែលដើរមុនខ្ញុំ ជាប្រធាននៃសាសនាចក្រ ។ ពួកលោកភាគច្រើន ខ្ញុំបានស្គាល់ដោយផ្ទាល់ ។ ខ្ញុំមានពរជ័យ និងកិត្តិយសក្នុងការបំរើជាទីប្រឹក្សាមួយរូបចំពោះពួកលោកទាំងបី ។ ខ្ញុំមានអំណរគុណចំពោះមរតកជាយូរអង្វែងដែលបានបន្សល់ទុកដោយពួកលោកមួយរូបៗ នៃបុរសទាំង 15 រូបនោះ ។ ខ្ញុំមានចំណេះដឹងយ៉ាងពិតប្រាកដ ដូចដែលខ្ញុំមានទំនុកចិត្តថាពួកលោកមាន ដែលថាព្រះដឹកនាំព្យាការីរបស់ទ្រង់ ។ ការអធិស្ឋានដោយក្លៀវក្លារបស់ខ្ញុំ គឺថាខ្ញុំអាចបន្តមានភាពសក្តិសមធ្វើជាឧបករណ៍នៅក្នុងព្រះហស្តរបស់ទ្រង់ ដើម្បីអនុវត្តកិច្ចការមហិមានេះ និងដើម្បីបំពេញទំនួលខុសត្រូវដ៏ធំធេងទាំងឡាយ ដែលមាននៅក្នុងការិយាល័យរបស់ប្រធាន ។

ខ្ញុំអរគុណចំពោះព្រះអម្ចាស់សំរាប់ទីប្រឹក្សាដ៏អស្ចារ្យ ។ ប្រធាន ហិនរី ប៊ី អាវរិង និងប្រធាន ដាយថើ អេស្វ អុជដូហ្វ គឺជាបុរសដែលមានសមត្ថភាពអស្ចារ្យ និងការយល់ដឹងយ៉ាងជ្រាលជ្រៅ ។ ពួកលោកគឺជាទីប្រឹក្សាដែលនៅពិតចំពោះពាក្យ ។ ខ្ញុំឱ្យតម្លៃទៅលើការវិនិច្ឆ័យរបស់ពួកលោក ។ ខ្ញុំជឿថាពួកលោក ត្រូវបានរៀបចំដោយព្រះអម្ចាស់ សំរាប់តំណែងទាំងឡាយ ដែលពួកគេធ្វើការឥឡូវនេះ ។ ខ្ញុំស្រឡាញ់សមាជិកទាំងឡាយ នៃក្រុមនៃពួកសាវកដប់ពីរនាក់ ហើយរក្សាទុកនូវទំនាក់ទំនងរបស់ខ្ញុំជាមួយពួកលោក ។ ពួកលោកបានលះបង់ចំពោះកិច្ចការបរិសព្រះអម្ចាស់ផងដែរ ហើយកំពុងតែចំណាយពេលរស់នៅរបស់ពួកលោក នៅក្នុងការបំរើរបស់ព្រះអម្ចាស់ ។ ខ្ញុំទន្ទឹងចាំបំរើជាមួយនឹងអែលឌើរ គ្រីស្តូហ្វឺរសិន ដែលឥឡូវនេះ ត្រូវបានហៅឱ្យចូលក្នុងក្រុមនោះ ហើយដែលបានទទួលមតិគាំទ្ររបស់អ្នក ។ ផងដែរ លោកត្រូវបានរៀបចំ

សំរាប់តំណែងដែលលោកត្រូវបានហៅឱ្យបំរើ ។ វាតែងតែជាក្ដីអំណរមួយដើម្បីបំរើ ជាមួយនឹងសមាជិកនៃក្រុមនៃពួក 70 នាក់ និងគណៈប៊ីស្សពជាអធិបតីផងដែរ ។ សមាជិកថ្មីនៃគណៈប្រធាន 70 នាក់ ត្រូវបានហៅ និងបានគាំទ្រកាលពីម្សិលមិញ ហើយខ្ញុំទន្ទឹងរង់ចាំដើម្បីទំនាក់ទំនងជាមួយពួកលោកនៅក្នុងកិច្ចការរបស់លោកចៅហ្វាយ ។

អារម្មណ៍ដ៏ផ្អែមល្ហែមមួយនៃសាមគ្គីភាព មាននៅក្នុងចំណោមពួកអ្នកមានសិទ្ធិអំណាចទូទៅ ។ ព្រះអម្ចាស់បានប្រកាសថា "បើសិនជាអ្នករាល់គ្នាមិនរួមគ្នាតែមួយទេ ឈ្មោះថាអ្នករាល់គ្នាពុំមែនជារបស់ផងយើងឡើយ" ។ 1 យើងនឹងបន្តរួបរួមគ្នានៅក្នុងគោលបំណងតែមួយ--- គឺភាពចំរើននៃកិច្ចការរបស់ព្រះអម្ចាស់ ។

ខ្ញុំទទួលអារម្មណ៍ឱ្យសម្ដែងនូវអំណរគុណចំពោះព្រះវរបិតាសួគ៌របស់ខ្ញុំ ចំពោះពរជ័យដែលរាប់មិនអស់របស់ទ្រង់ប្រទានដល់ខ្ញុំ ។ ខ្ញុំអាចនិយាយ ដូចជានីហ្វៃពីជំនាន់ដើមថា ខ្ញុំបានកើតមកពីឪពុកម្ដាយល្អ ដែលឪពុកម្ដាយ និងជីដូនជីតារបស់ពួកគាត់ ត្រូវបាននាំចេញមកពីទឹកដីស៊ុយអ៊ែត និងស្កុតឡែន និងប្រទេសអង់គ្លេស ដោយពួកអ្នកផ្សព្វផ្សាយសាសនាដែលមានការលះបង់ ។ នៅពេលពួកអ្នកផ្សព្វផ្សាយសាសនាទាំងនោះ ថ្លែងទីបន្ទាល់ដោយវាបសារ នោះទីបន្ទាល់បានប៉ះនឹងដួងចិត្ត និងវិញ្ញាណនៃជីដូនជីតារបស់ខ្ញុំ ។ បន្ទាប់ពីចូលរួមនៅក្នុងសាសនាចក្រ បុរស ស្ត្រី និងកុមារថ្លៃថ្នូរទាំងនោះ បានធ្វើដំណើរទៅកាន់ជ្រលងភ្នំសលត៍ លេកដ៏ធំ ។ មាននូវឧបសគ្គ និងការឈឺចាប់យ៉ាងច្រើន ដែលពួកគេបានជួបប្រទះនៅតាមផ្លូវ ។

នៅនិទាឃរដូវឆ្នាំ 1848 ជីដូនជីតាលួតរបស់ខ្ញុំ ឈ្មោះ ឆាល ស្ទូវើត មីលើរ និង ម៉ារី ម៉ាក់ហ្គូវ៉ាន មីលើរ ដែលបានចូលរួមក្នុងសាសនាចក្រនៅក្នុងប្រទេសកំណើតរបស់ពួកគាត់នៅស្កុតឡែន បានចាកចោលផ្ទះរបស់ពួកគាត់នៅរ៉ូស្ស៊ើរហ្គលែន ប្រទេសស្កុតលែន ហើយធ្វើដំណើរទៅកាន់ សេន លូអីស មីស្សូរី ជាមួយនឹងក្រុមពួកបរិសុទ្ធមួយក្រុម មកដល់ទីនោះនៅឆ្នាំ 1849 ។ កូនម្នាក់ក្នុងចំណោមកូន 11 នាក់របស់ពួកគាត់ ឈ្មោះ ម៉ាហ្គារ៉េត បានក្លាយទៅជាជីដូនទួតរបស់ខ្ញុំ ។

ខណៈដែលគ្រួសារនៅក្នុង សេន លូអីស ធ្វើការរកប្រាក់បានគ្រប់គ្រាន់ដើម្បីបញ្ចប់ការធ្វើដំណើររបស់ពួកគាត់ទៅកាន់ជ្រលងភ្នំសលត៍ លេក នោះមានរោគចង្រៃនៃជំងឺអាសន្នរោគ បានកើតឡើងនៅក្នុងតំបន់ ដែលបន្សល់ទុកនូវមនុស្សស្លាប់ និងអ្នកឈឺចាប់នៅពីខាងក្រោយ ។ គ្រួសារ មីលើរ ទទួលរងយ៉ាងធ្ងន់ធ្ងរ ។ ក្នុងរវាងពីរសប្ដាហ៍ សមាជិកគ្រួសារបួនរូបត្រូវបានស្លាប់ ។ អ្នកទីមួយនៅថ្ងៃទី 22 ខែ មិថុនា ឆ្នាំ 1849 មានអាយុ 18 ឆ្នាំ ឈ្មោះ វីល្លាម ។ ប្រាំថ្ងៃក្រោយមក ម៉ារី ម៉ាក់ហ្គូវ៉ាន មីលើរ ជាជីដូនលួតរបស់ខ្ញុំ និងជាម្ដាយក្នុងគ្រួសារ បានទទួលមរណភាព ។ ហើយនៅពីថ្ងៃបន្ទាប់ពីនោះ អានីបាល អាយុ 15 ឆ្នាំ បានទទួលមរណភាពដែរ និងប្រាំថ្ងៃបន្ទាប់ពីគាត់ស្លាប់ ជីតាលួតរបស់ខ្ញុំ ឈ្មោះ ឆាលឡេស ស្ទូវើត មីលើរ និងជាឪពុកក្នុងគ្រួសារក៏បានទទួលមរណភាព ។ កូនដែលនៅរស់រានមានជីវិត ត្រូវបានក្លាយជាក្មេងកំព្រា រួមមានទាំងជីដូនទួតរបស់ខ្ញុំ ឈ្មោះ ម៉ាហ្គារ៉េត ដែលមានអាយុ 13 ឆ្នាំនៅពេលនោះ ។

ដោយសារតែមានមនុស្សស្លាប់ជាច្រើននៅក្នុងតំបន់ នោះគ្មានក្ដារមឈូសទេ មិនថាឱ្យប្រាក់ប៉ុន្មានក៏ដោយ ដូច្នេះ ត្រូវកប់សពសមាជិគ្រួសារដែលទទួលមរណភាព ។ កូនប្រុសដែលនៅរស់ធំជាងគេ បានរុះយកចំណែករទេះគោរបស់គ្រួសារ ដើម្បីធ្វើជាក្ដារមឈូសសំរាប់សមាជិកគ្រួសារដែលបានស្លាប់ទៅ ។

មានការកត់ត្រាបន្តិចបន្តួចអំពីការឈឺចាប់ និងឧបសគ្គ របស់កូនចៅមីលើរ ដែលនៅសល់ប្រាំបួននាក់ នៅពេលពួកគេបន្តធ្វើការ និងសន្សំប្រាក់សំរាប់ការធ្វើដំណើរដែលឪពុកម្ដាយ និងបងប្អូនប្រុសរបស់ពួកគេមិនអាចបន្តទៅ

ទៀតបាន។ យើងដឹងថាពួកគេបានចាកចេញពីសេន លូអីស នៅក្នុងនិទាឃរដូវឆ្នាំ 1850 ដោយរទេះមួយ និងគោបួនក្បាល ទីបំផុតមកដល់ជ្រលងភ្នំសលត៍ លេកនៅក្នុងឆ្នាំដដែល។

ជីដូនជីតារបស់ខ្ញុំដទៃទៀតជួបប្រទះនឹងការលំបាកស្រដៀងគ្នានេះ។ តាមរយៈអ្វីទាំងអស់នោះ ទោះជាយ៉ាងណាក៏ដោយ ទីបន្ទាល់របស់ពួកគាត់ បាននៅខ្ជាប់ខ្ជួន និងរឹងប៉ឹង។ ចេញមកពីពួកគាត់ទាំងអស់គ្នា ខ្ញុំបានទទួលមរតក នៃការលះបង់ទាំងស្រុងចំពោះដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ លទ្ធផលនៃព្រលឹងស្មោះត្រង់ទាំងនោះ ខ្ញុំបានឈរនៅចំពោះមុខអ្នករាល់គ្នាក្នុងថ្ងៃនេះ។

ខ្ញុំអរគុណចំពោះព្រះវរបិតារបស់ខ្ញុំ ដែលគង់នៅស្ថានសួគ៌សំរាប់ដៃគូដ៏ល្អរបស់ខ្ញុំ ហ្វ្រែនស៊ីស។ ខែ តុលានេះ គាត់ និងខ្ញុំនឹងប្រារព្ធខួបអាពាហ៍ពិពាហ៍ដ៏អស្ចារ្យគំរប់ 60 ឆ្នាំរបស់យើង។ ថ្វីត្បិតតែការបំរើសាសនាចក្ររបស់ខ្ញុំចាប់ផ្តើម តាំងពីនៅក្មេងក៏ដោយ ក៏គាត់មិនដែលរអ៊ូរទាំ នៅពេលខ្ញុំចេញពីផ្ទះដើម្បីទៅចូលរួមប្រជុំ ឬបំពេញកិច្ចការនោះដែរ។ អស់រយៈពេលជាច្រើនឆ្នាំ កិច្ចការរបស់ខ្ញុំក្នុងនាមជាសមាជិកនៃពួកដប់ពីរនាក់ បាននាំឱ្យខ្ញុំចេញពីទីក្រុងសលត៍ លេកជារឿយៗ--- ពេលខ្លះម្តងៗត្រូវចំណាយពេលអស់ប្រាំសប្តាហ៍--- បានទុកគាត់ចោលម្នាក់ឯង ឱ្យមើលថែកូនតូចៗ និងគេហដ្ឋានរបស់យើង។ ដែលបានចាប់ផ្តើមតាំងពីខ្ញុំត្រូវបានហៅជាប៊ីស្សពនៅអាយុ 22 ឆ្នាំ យើងកំរនឹងមានការអង្គុយជុំគ្នាដ៏ប្រណិតនៅអំឡុងពេលកម្មវិធីសាសនាចក្រណាស់។ ខ្ញុំមិនអាចសុំឱ្យមានដៃគូដែលមានភក្តីភាព ក្តីស្រឡាញ់ និងការយល់ដឹងល្អជាងនេះទៀតទេ។

ខ្ញុំបង្ហាញនូវការដឹងគុណចំពោះព្រះវរបិតាសួររបស់ខ្ញុំចំពោះកូនបីនាក់របស់យើង និងដៃគូរបស់ពួកគេ និងចៅដ៏អស្ចារ្យចំនួនប្រាំបីនាក់ ព្រមទាំងចៅតួតដ៏អស្ចារ្យចំនួនបួននាក់ទៀត។

វាគឺជាការលំបាកសំរាប់ខ្ញុំដើម្បីរកពាក្យមកប្រាប់អ្នករាល់គ្នា បងប្អូនប្រុសស្រីរបស់ខ្ញុំអើយ ថាដួងចិត្តរបស់ខ្ញុំមានអំណរគុណចំពោះជីវិតដែលអ្នករស់នៅ ចំពោះសេចក្តីល្អដែលអ្នកធ្វើ ចំពោះទីបន្ទាល់ដែលអ្នកបានចែកចាយ។ អ្នកបំរើគ្នាទៅវិញទៅមកដោយស្ម័គ្រចិត្ត។ អ្នកបានលះបង់ដើម្បីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។

អំឡុងពេលជាង 44 ឆ្នាំក្នុងនាមជាអ្នកមានសិទ្ធិអំណាចទូទៅមួយរូប ខ្ញុំមានឱកាសដើម្បីធ្វើដំណើរទៅជុំវិញពិភពលោក។ ក្តីអំណរដ៏ធំបំផុតរបស់ខ្ញុំមួយ គឺពេលបានជួបនឹងអ្នករាល់គ្នា ជាសមាជិក នៅគ្រប់ទីកន្លែង--- ដើម្បីទទួលអារម្មណ៍នៃវិញ្ញាណ និងក្តីស្រឡាញ់របស់អ្នក។ ខ្ញុំទន្ទឹងរងចាំនូវឱកាសកាន់តែច្រើនដូច្នេះទៀត។

នៅក្នុងការធ្វើដំណើរលើផ្លូវជីវិតដ៏វែងឆ្ងាយមកនេះ មានមនុស្សជាច្រើនដែលបានលាចាកទៅ។ អ្នកខ្លះបានលាចាកពីស្លាកសញ្ញាប្រាប់ផ្លូវ ដែលចង្អុលទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច ដែលរកឃើញតែផ្លូវបត់នាំទៅរកផ្លូវទាល់នៅទីបំផុត។ ការព្រងើយកន្តើយ មិនយកចិត្តទុកដាក់ អត្មានិយម និងអំពើបាប ទាំងអស់នេះបានដកយកតម្លៃដែលពួកគេមានពីក្នុងជីវិតរស់នៅរបស់មនុស្ស។

ការផ្លាស់ប្តូរទៅរកភាពប្រសើរឡើងអាចកើតមានចំពោះមនុស្សទាំងអស់។ អស់រយៈពេលជាច្រើនឆ្នាំយើងបានអំពាវនាវហៅអ្នកមិនសូវសកម្ម អ្នកដែលបានអន់ចិត្ត អ្នកដែលរិះគន់ និងអ្នករំលង--- ឱ្យត្រឡប់មកវិញ។ " ត្រឡប់មក ហើយទទួលទាននៅតុរបស់ព្រះអម្ចាស់ ហើយភ្លក់រស់ជាតិផ្លែឈើផ្អែមល្ហែម និងបំពេញចិត្តរបស់បងប្អូន ជាមួយនឹងពួកបរិសុទ្ធ"។2

នៅក្នុងការញែកឱ្យបរិសុទ្ធផ្ទាល់ខ្លួន នៃមនសិការរបស់មនុស្សម្នាក់ ពឹងផ្អែកលើវិញ្ញាណ និងការប្តេជ្ញាចិត្តដើម្បីបណ្តេញចេញនូវរូបចាស់ ហើយតំឡើងរង្វាស់ទៅដល់កំរិតនៃសក្តានុពលពិត។ នៅក្នុងអារម្មណ៍នេះ យើងសូមចេញនូវការអញ្ជើញដោយអស់ពីដួងចិត្តម្តងទៀតថាៈ ចូរត្រឡប់មកវិញ។ យើងឈោងទៅរកអ្នកនៅក្នុងសេចក្តីស្រឡាញ់ដ៏បរិសុទ្ធរបស់ព្រះគ្រីស្ទ ហើយបង្ហាញនូវបំណងប្រាថ្នារបស់យើងដើម្បីជួយដល់អ្នក និងស្វាគមន៍អ្នកឱ្យទទួលការរាប់អានពេញលេញ។ ចំពោះអ្នកទាំងឡាយដែលមានរបួសក្នុងវិញ្ញាណ ឬអ្នកដែលមានឧបសគ្គ និងភាពភ័យខ្លាច យើងនិយាយថា សូមឱ្យយើងលើកអ្នកឡើង ហើយឱ្យអ្នករីករាយ និងរំងាប់ភាពភ័យខ្លាចរបស់អ្នក។ សូមទទួលយកការអញ្ជើញរបស់ព្រះអម្ចាស់ដោយស្មោះថា "អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឱ្យអ្នករាល់គ្នាឈប់សំរាក។ ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ត្បិតខ្ញុំស្លូត ហើយមានចិត្តសុភាព នោះអ្នករាល់គ្នានឹងបានសេចក្តីសំរាកដល់ព្រលឹង។ ពីព្រោះនឹមខ្ញុំងាយទេ ហើយបន្ទុកខ្ញុំក៏ស្រាល"។[3]

ព្រះអង្គសង្គ្រោះបានមានបន្ទូលថា ទ្រង់ "បានយាងចុះឡើងធ្វើការល្អ... ត្បិតព្រះបានគង់នៅជាមួយនឹងទ្រង់"។[4] សូមឱ្យយើងធ្វើតាមគំរូដ៏ឥតខ្ចោះនេះ។ នៅក្នុងរឿងនេះពេលខ្លះការធ្វើដំណើរដែលមិនប្រាកដប្រជា នៅក្នុងជីវិតរមែងស្លាប់ សូមឱ្យយើងបានធ្វើតាមដំបូន្មាន មកពីសាវកប៉ុលផងដែរ ដែលនឹងជួយរក្សាយើងឱ្យមានសុវត្ថិភាព និងស្ថិតនៅលើផ្លូវៈ "ឯសេចក្តីណាដែលពិត សេចក្តីណាដែលគួររាប់អាន សេចក្តីណាដែលសុចរិត សេចក្តីណាដែលបរិសុទ្ធ សេចក្តីណាដែលគួរស្រឡាញ់ សេចក្តីណាដែលមានឈ្មោះល្អ បើមានសគុណណា ឬជាសេចក្តីសរសើរណា នោះចូរពិចារណាពីសេចក្តីទាំងនោះចុះ"។[5]

ខ្ញុំលើកទឹកចិត្តដល់សមាជិកនៃសាសនាចក្រ គ្រប់ទីកន្លែងឱ្យបង្ហាញសន្តានចិត្តល្អ និងគោរពដល់មនុស្សទាំងអស់នៅគ្រប់ទីកន្លែង។ ពិភពលោកដែលយើងរស់នៅគឺពោរពេញទៅដោយភាពខុសគ្នា។ យើងអាច និងគួរតែបង្ហាញនូវការគោរព ចំពោះអ្នកទាំងឡាយណាដែលមានជំនឿខុសពីយើង។

សូមឱ្យយើងបង្ហាញសន្តានចិត្តល្អ និងសេចក្តីស្រឡាញ់នៅក្នុងរង្វង់គ្រួសារផ្ទាល់របស់យើងផងដែរ។ គេហដ្ឋានរបស់យើងគឺត្រូវធ្វើឱ្យជាកន្លែងដែលលើសពីមានសុវត្ថិភាព វាគួរតែជាកន្លែងដែលព្រះវិញ្ញាណរបស់ព្រះ អាចគង់នៅផងដែរ ជាកន្លែងដែលព្យុះនឹងបញ្ឈប់នៅត្រឹមមាត់ទ្វារ ជាកន្លែងដែលគ្រងសេចក្តីស្រឡាញ់ និងសេចក្តីសុខសាន្តស្ថិតនៅ។

ជួនកាលពិភពលោកអាចជាកន្លែងដែលគួរឱ្យភ័យខ្លាចដើម្បីរស់។ តម្លៃខាងសីលធម៌របស់សង្គម ហាក់ដូចជាធ្លាក់ចុះនៅក្នុងល្បឿនមួយដ៏លឿន។ ដែលគ្មាននរណាម្នាក់---មិនថាចាស់ ឬក្មេង ឬវ័យកណ្តាល---ត្រូវបានលើកលែងពីការសាយភាយចំពោះរឿងទាំងនោះ ដែលមានឥទ្ធិពលយ៉ាងខ្លាំង ដើម្បីទាញយើងឱ្យធ្លាក់ចុះ និងបំផ្លាញយើងនោះទេ។ ជាពិសេស យុវវ័យរបស់យើង យុវវ័យដ៏មានតម្លៃរបស់យើង ប្រឈមមុខនឹងការល្បួងទាំងឡាយ ដែលយើងអាចនឹងយល់ដឹងដោយមិនដឹតដល់។ សត្រូវ និងកងពលរបស់វា ហាក់ដូចជាកំពុងធ្វើការគ្មានឈប់ឈរ ដើម្បីបណ្តាលឱ្យយើងធ្លាក់ចុះ។

យើងកំពុងតែធ្វើសង្គ្រាមប្រឆាំងនឹងអំពើបាប បងប្អូនប្រុសស្រីទាំងឡាយរបស់ខ្ញុំ ប៉ុន្តែយើងមិនចាំបាច់អស់សង្ឃឹមនោះទេ។ វាគឺជាសង្គ្រាមមួយដែលយើងអាច ហើយនឹងបានទទួលជោគជ័យ។ ព្រះវរបិតា ដែលគង់នៅស្ថានសួគ៌របស់យើងបានប្រទានដល់យើងនូវឧបករណ៍ជាច្រើនដែលយើងត្រូវការដើម្បីធ្វើសង្គ្រាម។ ទ្រង់ជាអ្នកគ្រប់គ្រង។

យើងមិនបាច់ខ្លាចអ្វីឡើយ។ ទ្រង់គឺជាព្រះនៃពន្លឺ។ ទ្រង់គឺជាព្រះនៃក្ដីសង្ឃឹម។ ខ្ញុំសូមធ្វើទីបន្ទាល់ថា ទ្រង់ស្រឡាញ់យើង--- ម្នាក់ៗ។

ជីវិតរមែងស្លាប់គឺជារយៈពេលនៃការសាកល្បង ជាពេលដើម្បីបង្ហាញថាខ្លួនយើងសក្ដិសមដើម្បីត្រឡប់ទៅកាន់វត្តមានរបស់ព្រះវរបិតាសួគ៌របស់យើងវិញ។ ដើម្បីត្រូវបានសាកល្បង ពេលខ្លះយើងត្រូវតែប្រឈមមុខនឹងឧបសគ្គ និងការលំបាកទាំងឡាយ។ ពេលខ្លះគ្មានពន្លឺនៅចុងផ្លូវរូងដីទេ--- គ្មានពន្លឺដើម្បីបំបែកភាពងងឹតនៃពេលរាត្រី។ យើងមានអារម្មណ៍គ្របដណ្ដប់ដោយភាពឈឺចាប់ នៃដួងចិត្តខ្ទេចខ្ទាំ បាក់ទឹកចិត្តដែលសុបិនត្រូវបានបែកខ្ចាយ ហើយក្ដីអស់សង្ឃឹមបានបំផ្លាញក្ដីសង្ឃឹម។ យើងចូលរួមនៅក្នុងសំឡេងអង្វរក្នុងគម្ពីរប៊ីបថា "តើគ្មានប្រទាលមុខសះនៅស្រុកកាឡាតទេឬអី?" 6 យើងបែរជាទោរទៅមើលភាពអត់សំណាងផ្ទាល់ខ្លួនរបស់យើង តាមរយៈព្រីស្មដែលកោងនៃភាពទុទិដ្ឋិនិយម។ យើងមានអារម្មណ៍ថាត្រូវបោះបង់ចោល ខូចចិត្ត នៅតែម្នាក់ឯង។ បើអ្នកឃើញថាខ្លួនអ្នកនៅក្នុងស្ថានភាពដូច្នេះ ខ្ញុំសូមអង្វរអ្នកឱ្យត្រឡប់ទៅរកព្រះវរបិតាសួគ៌របស់យើងនៅក្នុងសេចក្ដីជំនឿ។ ទ្រង់នឹងលើកអ្នកឡើង ហើយដឹកនាំអ្នក។ ទ្រង់នឹងមិនតែងតែដកយកការរងទុក្ខទាំងឡាយរបស់អ្នកពីអ្នកទេ ប៉ុន្តែទ្រង់នឹងលួងលោម ហើយដឹកនាំអ្នកដោយក្ដីស្រឡាញ់ឆ្លងកាត់ព្យុះភ្លៀងដែលអ្នកប្រឈមមុខ។

ដោយអស់ពីដួងចិត្តរបស់ខ្ញុំ និងភាពកក់ក្ដៅនៃព្រលឹងរបស់ខ្ញុំ ខ្ញុំសូមបន្លឺសំឡេងរបស់ខ្ញុំធ្វើទីបន្ទាល់នៅថ្ងៃនេះក្នុងនាមជាសាក្សីពិសេសមួយរូប ហើយប្រកាសថាព្រះមានព្រះជន្មរស់។ ព្រះយេស៊ូវគឺជាព្រះរាជបុត្រារបស់ទ្រង់ ជាបុត្រជាទីស្រឡាញ់តែមួយគត់របស់ព្រះវរបិតានៅក្នុងសាច់ឈាម។ ទ្រង់គឺជាព្រះប្រោសលោះរបស់យើង ទ្រង់គឺជាអង្គសង្គ្រោះសង្គ្រមរបស់យើងជាមួយនឹងព្រះវរបិតា។ ទ្រង់ស្រឡាញ់យើងដោយក្ដីស្រឡាញ់មួយដែលយើងមិនអាចយល់បានពេញលេញ ហើយដោយសារទ្រង់ស្រឡាញ់យើង ទ្រង់បានប្រទានជីវិតរបស់ទ្រង់សំរាប់យើង។ ការដឹងគុណរបស់ខ្ញុំចំពោះទ្រង់គឺហួសនឹងអាចថ្លែងបាន។

ខ្ញុំអធិស្ឋានសុំឱ្យពរជ័យទាំងឡាយរបស់ទ្រង់មានមកលើអ្នករាល់គ្នា បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំនៅក្នុងគេហដ្ឋានរបស់អ្នក នៅក្នុងកន្លែងការងាររបស់អ្នក នៅក្នុងការបំរើរបស់អ្នកចំពោះគ្នាទៅវិញទៅមក និងចំពោះព្រះអម្ចាស់ទ្រង់ផ្ទាល់។ យើងគួរតែឆ្ពោះទៅមុខជាមួយគ្នាក្នុងការធ្វើកិច្ចការរបស់ទ្រង់។

ខ្ញុំសន្យាជីវិតរបស់ខ្ញុំ កម្លាំងរបស់ខ្ញុំ--- អ្វីទាំងអស់ដែលខ្ញុំមានដើម្បីផ្ដល់ឱ្យ--- នៅក្នុងការបំរើទ្រង់ និងនៅក្នុងការដឹកនាំកិច្ចការនៃសាសនាចក្ររបស់ទ្រង់ ស្របតាមឆន្ទៈរបស់ទ្រង់ និងតាមការបំផុសគំនិតរបស់ទ្រង់ ហើយខ្ញុំសូមធ្វើដូច្នោះនៅក្នុងព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់--- ជាព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ--- អាម៉ែន។

កំណត់ចំណាំ

1. គោលលទ្ធិ និងសេចក្ដីសញ្ញា 38:27។

2. សេចក្ដីថ្លែងរបស់គណៈប្រធានទីមួយនៅក្នុង *Ensign,* ខែ មិនា ឆ្នាំ 1986, ទំព័រ 88។

3. ម៉ាថាយ 11:28-30។

4. កិច្ចការ 10:38។

5. ភីលីព 4:8 ។

6. យេរេមា 8:22 ។